ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

7

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

7

# អត្ថហេតុចម្បង និងការសរ

# សេរពាក្យបណ្តឹង

**បទបង្ហាញដោយៈ មេធាវី រស់ អម្រិត**

ប្រព្រឹត្តនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥

# ✍ អត្ថន័យនៃបណ្ដឹង

គឺជាសកម្មភាពទាមទារ ដែលធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយ ដោយបានអះអាងអំពីអត្ថិភាព ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ តាមរយៈការដាក់ពាក្យបណ្ដឹង ។

# ✍ តើបណ្ដឹងមានប៉ុន្មានប្រភេទ?

- ☞ បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក
- ☞ បណ្ដឹងទាមទារឲ្យបញ្ជាក់
- ☞ បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

# ១. តើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកគឺជាអ្វី?

ជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក យោងតាមការកំនត់តាមផ្លូវច្បាប់សារធាតុ ។

## ✍ តើការទាមទារតាមរយៈបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកមានអ្វីខ្លះ?

- ការទាមទារប្រាក់ជាក់លាក់
- ការទាមទារឲ្យប្រគល់អចលនវត្ថុជាក់លាក់ (ដី ឬផ្ទះ)
- ការទាមទារឲ្យប្រគល់ចលនវត្ថុកំណត់ជាក់លាក់
- ការទាមទារឲ្យបង្ហាញឆន្ទៈកំណត់មួយ
- ការទាមទារឲ្យធ្វើ ឬមិនធ្វើសកម្មភាពកំណត់ណាមួយ

ឧទ្ទេសនាមដោយៈ មេធាវី រស់ អម្រិត

# ✍ តើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកអាចធ្វើឡើងនៅពេលណា?

✓ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន

✓ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត

## ** ការចេញសាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

## ២. តើបណ្តឹងទាមទារឲ្យបញ្ជាក់គឺជាអ្វី ?

គឺជាបណ្តឹងដែលដើមចោទទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទនូវ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តមួយកំនត់យ៉ាងជាក់លាក់ក្នុងបណ្តឹង ។

- ❑ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិហៅថា **“បណ្តឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម”**
- ❑ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិហៅថា **“បណ្តឹងទាមទារឲ្យបញ្ជាក់ ដោយអកម្ម”**

ឧទ្ទេសនាមដោយៈ មេធាវី រស់ អម្រិត

# កម្មវត្ថុនៃបណ្ដឹងទាមទារឲ្យបញ្ជាក់

- គោលការណ៍៖ បញ្ជាក់តែអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលមានជាក់ស្ដែង ។ ករណីលើកលែង៖ មិនបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះទេ ។

- គោលការណ៍៖ កម្រិតត្រឹមការទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ “នាពេលបច្ចុប្បន្ន” មិនអនុញ្ញាតឲ្យធ្វើក្នុងអតីតកាល ឬអនាគតកាលឡើយ ។ ករណីលើកលែង៖ យោងតាមភាពចាំបាច់ក្នុងការដោះស្រាយវិវាទនាពេលបច្ចុប្បន្ន។

## ***ការចេញសាលក្រមនៃបណ្ដឹងទាមទារឲ្យបញ្ជាក់

## ៣. តើបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តគឺជាអ្វី ?

គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត (ការកកើតឡើង ការប្តូរ ឬការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬអំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តដែលកំណត់ជាក់ លាក់ ដោយការដាក់ពាក្យបណ្តឹង ។

ឧទ្ទេសនាមដោយៈ មេធាវី រស់ អម្រិត

## កម្មវត្ថុនៃបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

- ត្រូវមានការអះអាងអំពីអត្ថិភាពនៃសិទ្ធិតាមទំនាក់ទំនងនោះ ឬអំពីអត្ថិភាពនៃមូលហេតុ ក្នុងការបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ។

- ករណីនៃបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តតាមទម្រង់ ។

## ***ការចេញសាលក្រមចំពោះបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

ឧទ្ទេសនាមដោយៈ មេធាវី រស់ អម្រិត